រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃ ព្រហស្បតិ៍ ទី ២៤ ខែ មិថុនា ឆ្នាំ ២០១០

## របាយការណ៍សំយោគទី ២៤ របស់គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ

## វិស័យកាត់ដេរបង្ហាញសញ្ញានៃការងើបឡើងវិញ

ភ្នំពេញ ប្រទេសកម្ពុជា- គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) នៅថ្ងៃនេះ ចេញផ្សាយនូវរបាយការណ៍សំយោគទី ២៤ ស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរកម្ពុជា ដែលធ្វើការវាយតំលៃលើការអនុលោមទៅតាមច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារអន្តរជាតិនៅក្នុងរោងចក្រកាត់ដេរនាំចេញ។

របាយការណ៍សំយោគ ទី ២៤ នេះ ឆ្លុះបញ្ចាំងពីទិន្នន័យនៃការអនុលោមតាមច្បាប់ពីរបាយការណ៍ត្រួតពិនិត្យរោងចក្រចំនួន១៥៧ ដែលត្រូវបានបញ្ចប់នៅចន្លោះពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០។ របាយការណ៍នេះផ្ទុកនូវព័ត៌មានជាច្រើន រួមមានព័ត៌មានអំពីទំហំរោងចក្រនៅទូទាំងវិស័យនេះ ក៏ដូចជាទិន្នន័យប្រៀបធៀបអំពីការអនុលោមតាមសិទ្ធិជាមូលដ្ឋាន និងល័ក្ខខ័ណ្ឌការងារដែលត្រូវបានកំណត់ដើម្បីសម្រួលដល់ការតាមដាននូវកម្រិតនៃការអនុលោមតាមច្បាប់នាពេលកន្លងមក។

របាយការណ៍សំយោគទី ២៤ នេះគឺជារបាយការណ៍លើកដំបូងហើយដែលបង្ហាញពីការកើនឡើងនូវកម្រិតការងារ បើប្រៀបធៀបទៅនឹងរបាយការណ៍មុនៗ ចាប់តាំងពីរបាយកាណ៍សំយោគទី ២១ ដែលធ្វើឡើងកាលពីថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០០៨។ កម្រិតការងារបានកើនឡើងបន្តិចចាប់តាំងពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ បើទោះបីជាមានការបិទរោងចក្រមួយចំនួនបន្ថែមទៀតក៏ដោយ។ ទោះបីជាកម្រិតការងារនៅតែមានការធ្លាក់ចុះកាលពីឆ្នាំមុនក៏ដោយ ក៏ការបាត់បង់ការងារដែលកើតឡើងដោយសារតែវិបត្តិនេះនៅមានកម្រិតថេរ ដូច ដែល បាន ឆ្លុះបញ្ចាំងតាមរយៈភាគរយថយចុះតិចតួចនៅក្នុងឆ្នាំកន្លងទៅ(៦%) បើប្រៀបធៀបជាមួយនឹងភាគរយដែលសង្កេតឃើញនៅក្នុងឆ្នាំមុនមួយទៀត (១២,៥%) ។ ទិន្នន័យរបស់ក្រសួងពាណិជ្ជកម្មក៏បានបង្ហាញពីការងើបឡើងវិញនៃវិស័យកាត់ដេរ ដោយកម្រិតនៃការនាំចេញក្នុងរយៈពេល ៥ ខែដំបូងនៃឆ្នាំ ២០១០ លើសពីកម្រិតនៃការនាំចេញនៅក្នុងរយៈដូចគ្នាកាលពីឆ្នាំទៅ។

ទោះបីជាកង្វល់លើបញ្ហាមួយចំនួននៅតែមាន ជាពិសេសទាក់ទងនឹងសេរីភាពក្នុងការបង្កើតអង្គការវិជ្ជាជីវៈ និងការរើសអើង ក៏ជាទូទៅ កម្រិតនៃការអនុលោមទៅតាមច្បាប់នៅតែមានកម្រិតខ្ពស់។ ការអនុលោមទៅនឹងការទូទាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតមានការកែលម្អខ្លះ នៅក្នុងបញ្ហាចំនួន ៤ ក្នុងចំណោមបញ្ហាចំនួន ៦ ដែលត្រូវបានរាយការណ៍។លើសពីនេះ

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

ទៅទៀត ការសិក្សាមួយដែល រៀបចំឡើងដោយអង្គការពលកម្មអន្តរជាតិ (ILO) ហើយដែលត្រូវបានអនុវត្ត ដោយវិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ បង្ហាញថា មានកម្មករនិយោជិតតិចតួចជាងមុន បានជួបនឹងការ ថយចុះនូវប្រាក់ចំណូលដោយសារតែការកាត់បន្ថយនូវម៉ោងធ្វើការធម្មតា និងម៉ោងធ្វើការបន្ថែម ការតម្រូវឱ្យសុំ ច្បាប់ឈប់សម្រាក និងការព្យួរការងារ នៅក្នុងឆ្នាំនេះ បើប្រៀបធៀបទៅនឹងត្រីមាសចុងក្រោយកាលពីឆ្នាំមុន។ ផ្ទុយទៅវិញ កម្មករនិយោជិតភាគច្រើនបានរាយការណ៍ថា ពួកគេមិនមានលុយគ្រប់គ្រាន់ដើម្បីចំណាយលើតម្រូវ ការជាមូលដ្ឋាន ដូចជា អាហារ ការស្នាក់នៅ និងការថែទាំសុខភាពជាដើម។

លទ្ធផលដែលបានរកឃើញសំខាន់ៗមួយចំនួន មានដូចតទៅ ៖

- វិស័យកាត់ដេរកំពុងបង្ហាញនូវសញ្ញានៃការងើបឡើងវិញពីវិបត្តិសេដ្ឋកិច្ច ហើយកម្រិតការងារមានការកើន ឡើងបន្តិចបន្តួច បើប្រៀបធៀបទៅនឹងរបាយការណ៍មុន។
- នាពេលថ្មីៗនេះ កម្មករនិយោជិតជាងពីរភាគបីកំពុងធ្វើការនៅក្នុងរោងចក្រដែលមានកម្មករនិយោជិត ចំនួន ១០០០នាក់ ឬច្រើនជាងនេះ បើទោះបីជាកាលពីឆ្នាំមុន មានការធ្លាក់ចុះចំនួន ៩% នូវរោងចក្រ ដែលមានកម្មករនិយោជិតពី ១០០០ នាក់ ទៅ ២០០០ នាក់ ។
- ៧៩% នៃរោងចក្រដែលបានត្រួតពិនិត្យមើល មានសហជីពយ៉ាងហោចណាស់មួយ ពោលគឺកើនឡើង ចំនួន៣% ពីរបាយការណ៍សំយោគទី ២៣។
- ការអនុលោមទៅតាមល័ក្ខខ័ណ្ឌដែលពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានមិនមានការផ្លាស់ប្តូរលើសពី ៣% បើ ប្រៀបធៀបទៅនឹងរបាយការណ៍មុន។ ភាគរយនៃចំនួនរោងចក្រដែលបានរើសអើងចំពោះកម្មករនិយោជិត (ជាធម្មតា ការរើសអើងលើភេទ) គឺមានចំនួន១៣% ពោលគឺកើនឡើងពី១០% ហើយភាគរយដែល មានការរើសអើងប្រឆាំងនឹងសហជីពគឺមានចំនួន ២% ពោលគឺកើនឡើងពី ១% ហើយភាគរយដែល រំខានដល់សេរីភាពសមាគមរបស់កម្មករនិយោជិតមានចំនួន ២% ដោយធ្លាក់ចុះពី ៣%។
- ពុំមានកម្មករនិយោជិតក្រោមអាយុត្រូវបានរកឃើញ ខណៈពេលដែលមានកម្មករនិយោជិតក្រោមអាយុ ចំនួន ១ នាក់នៅក្នុងរបាយការណ៍មុន។
- រោងចក្រចំនួន ៩% ក្នុងចំណោមរោងចក្រទាំងឡាយដែលត្រូវបានត្រួតពិនិត្យមើល មានកូដកម្ម ដែល ភាគរយនេះបានធ្លាក់ចុះពី ១៤% នៅក្នុងរបាយការណ៍មុន។
- ការអនុលោមទៅតាមល័ក្ខខ័ណ្ឌប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតពេញសិទ្ធិ គឺមានកម្រិត៩៩% ពោលគឺថយចុះពីកម្រិត ១០០% នៅក្នុងរបាយការណ៍មុន។ សម្រាប់កម្មករនិយោជិតម្តងម្កាលវិញ ការ អនុលោមទៅតាមច្បាប់ក្នុងការផ្តល់ប្រាក់ឈ្នួលអប្បបរមា គឺមានកម្រិត ៩៣% ពោលគឺកើនឡើងពី ៨៩% ក្នុងរោងចក្រដែលជួលកម្មករនិយោជិតម្តងម្កាល។
- រោងចក្រចំនួន ៩៨% បានផ្តល់ការឈប់សម្រាកប្រចាំឆ្នាំដែលមានរយៈពេល ១៨ ថ្ងៃ។ ការអនុលោម ទៅនឹងលក្ខខណ្ឌប្រាក់ឈ្នួលសម្រាប់ការឈប់សម្រាកលំហែមាតុភាព ធ្លាក់ចុះចំនួន ៧% ខណៈពេល ដែលការអនុលោមតាមល័ក្ខខ័ណ្ឌនៃការឈប់សម្រាកឈឺដោយមានប្រាក់ឈ្នួល គឺមានកម្រិត ៧៨% ពោលគឺកើនឡើង ៣% បើប្រៀបធៀបជាមួយនឹងរបាយការណ៍មុន។

- ការអនុលោមទៅតាមច្បាប់ស្តីពីកំហិតភាពញឹកញាប់ និងរយៈពេលនៃការធ្វើការបន្ថែមម៉ោង បានធ្លាក់ចុះចំនួន ៣% បើប្រៀបធៀបនឹងរបាយការណ៍មុន។ បើទោះបីជាមានការកើនឡើងនូវម៉ោងធ្វើការបន្ថែមក៏ដោយ ក៏ការធ្វើការបន្ថែមម៉ោងគឺជាការស្ម័គ្រចិត្ត ពោលគឺបានកើនឡើងចំនួន ៣%។
- ការអនុលោមទៅតាមល័ក្ខខ័ណ្ឌផ្តល់ឧបករណ៍ការពារខ្លួនកើនឡើងចំនួន ១% ចំណែកឯការតម្លើងរបាំងការពារម្ជុលលើម៉ាស៊ីនដេរ កើនឡើងចំនួន ៦%។
- ល័ក្ខខ័ណ្ឌធ្វើការបន្ថែមម៉ោង និងសុខភាព និងសុវត្ថិភាពការងារ មានបញ្ហាចំនួន ៨ ក្នុងចំណោមបញ្ហាធំៗចំនួន ១០ ដែលមិនត្រូវបានអនុលោមតាមច្បាប់ ដែលនេះបានឆ្លុះបញ្ចាំងពីបញ្ហាដ៏តឹងតែង ដែលនិយោជកជួបប្រទះនៅក្នុងការដោះស្រាយនូវបញ្ហាទាំងនេះ។ តែទោះបីយ៉ាងណាក៏ដោយ ក៏មានការកែលម្អនូវល័ក្ខខ័ណ្ឌមួយចំនួនដែលពាក់ព័ន្ធនឹងសុវត្ថិភាពសារធាតុគីមី។

«របាយការណ៍សំយោគទី ២៤ ស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា» មានជាភាសា**ខ្មែរ អង់គ្លេស** និង**ចិន** ដែលអាចរកបាននៅលើគេហទំព័រ www.betterfactories.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ
លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
អ៊ីម៉េលៈ ying@ilo.org
ទូរស័ព្ទៈ ០១២ ៩០ ២៩ ៩០